# អគ្គិសនីកម្ពុជាផ្តល់កិច្ចសន្យាសាងសង់គម្រោងពង្រីកអគ្គិសនីនៅក្នុងក្រុងភ្នំពេញឱ្យក្រុមហ៊ុនជប៉ុន

ដោយ : ស៊ា ចាំង

ភ្នំពេញ : ក្រុមហ៊ុនអគ្គិសនីកម្ពុជា បានឱ្យដឹងថា អគ្គិសនីកម្ពុជា បានចុះហត្ថលេខាប្រគល់កិច្ចសន្យាការងារឱ្យក្រុមហ៊ុនសម្ព័ន្ធជប៉ុន TOENEC Corporation & Sumitomo Electric Industrial &Siemens ដើម្បីអនុវត្តន៍គម្រោងពង្រីកខ្សែបញ្ជូន និងពង្រីកបណ្តាញចែកចាយអគ្គិសនីនៅក្រុងភ្នំពេញ ដែលមានទឹកប្រាក់ចំនួន ១.២៤៨លានយ៉េនជប៉ុន និងជាង៣៩លានដុល្លារអាមេរិក ។




អគ្គិសនីកម្ពុជាផ្តល់កិច្ចសន្យាសាងសង់គម្រោងពង្រីកអគ្គិសនីនៅក្នុងក្រុងភ្នំពេញឱ្យក្រុមហ៊ុនជប៉ុន (រូបថត:ស៊ា ចាំង)

នៅថ្ងៃទី១០ ឧសភា ឆ្នាំ២០១៨ នេះ នៅស្នាក់ការកណ្តាលអគ្គិសនីកម្ពុជា លោកកែវ រតនៈ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា បានចុះហត្ថលេខាលើកិច្ចសន្យាអនុវត្តន៍គម្រោងពង្រីកខ្សែបញ្ជូន និងពង្រីកបណ្តាញចែកចាយអគ្គិសនីនៅក្រុងភ្នំពេញ ជាមួយតំណាងនៃក្រុមហ៊ុនសម្ព័ន្ធជប៉ុន TOENEC Corporation & Sumitomo Electric Industrial & Siemens ដោយមានការចូលរួមពីតំណាងទីភ្នាក់ងារសហប្រតិបត្តិការជប៉ុន ឬចៃកា (JICA) ប្រចាំនៅកម្ពុជា ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រុមហ៊ុនអគ្គិសនីកម្ពុជា

តទៅទំព័រ ក7

# ហ្គាភាស់សាំងនៅចិនចាក់សាំងលែងប្រើលុយហើយ



គណៈប្រតិភូអ្នកសារពត៌មានចិន-អាស៊ាន ស្វែងយល់ពីប្រព័ន្ធទូទាត់តាមអ៊ីនធើណិតតាមស្ថានីយចាក់សាំង នៅទីក្រុងហាងចូវ ខេត្តជើជាំង កាលពីរសៀលថ្ងៃទី៩ខែឧសភាឆ្នាំ២០១៨ (រូបថត:សុផល,ពន្លក)

ដោយ: សុផល

ប្រាប់គណៈប្រតិភូអ្នកសារព័ត៌មានចិន-

ប្រើលុយនិងកាត ឥឡូវនេះគេប្រើតាម



*ឃាត់ខ្លួនជនសង្ស័យម្នាក់ពាក់ព័ន្ធគ្រឿងញៀន បញ្ជូនទៅតុលាការ (រូបថត:គូលែន)*

## ប៉េអឹមខេត្តសៀមរាបចាប់សង្ឃក្លែងក្លាយប្រាំនាក់ បញ្ជូនទៅសាលាដំបូង

***ដោយ: គូលែន***

**សៀមរាប :** ប៉េអឹមខេត្តសៀមរាប បានឃាត់ខ្លួនសង្ឃក្លែងក្លាយចំនួនប្រាំនាក់ពាក់ព័ន្ធនឹងការបន្លំខ្លួនធ្វើជាសង្ឃនៅចំណុចព្រះអង្គចេក ព្រះអង្គចម ស្ថិតនៅក្នុងភូមិមណ្ឌល២ សង្កាត់ស្វាយដង្គំ ក្រុង-ខេត្តសៀមរាប កាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨ ។

មន្ត្រីប៉េអឹមខេត្ត បានឱ្យដឹងថា សង្ឃក្លែងក្លាយទាំងប្រាំនាក់នោះ ១.ឈ្មោះ ផន ផាន់ណា អាយុ៣០ឆ្នាំ រស់នៅភូមិជ្រៃអូរភ្នៅ ឃុំវាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ, ២.ឈ្មោះ ឃួន ឃឿន អាយុ២៤ឆ្នាំ រស់នៅភូមិព្រៃក្មេង ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប, ៣.ឈ្មោះ ឯម វិចិត្រ អាយុ១៩ឆ្នាំ រស់នៅភូមិអូរក្រសារ ឃុំអូរក្រសារ ស្រុក អូរក្រសារ ខេត្តកែប, ៤.ឈ្មោះ ខាត់ សុខា អាយុ២២ឆ្នាំ រស់នៅភូមិព្រៃក្មេង ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប និង៥.ឈ្មោះ រឹម អាយុ១៧ឆ្នាំ រស់នៅភូមិត្រពាំងជ្រៅ ឃុំត្រពាំងជ្រៅ ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ។

ប្រភពបានបន្តថា ក្រោយការឃាត់ខ្លួនសង្ឃក្លែងក្លាយទាំងប្រាំនាក់រួចមក សមត្ថកិច្ចដកហូតវត្ថុតាងមួយចំនួនរួមមាន រថយន្តតូយ៉ូតា កាមរី ពណ៌ទឹកប្រាក់ ស៊េរីឆ្នាំ៩៥ ពាក់ស្លាកលេខ បន្ទាយមានជ័យ ២A-៥១៤១, ទូរស័ព្ទ

## ផ្ទះប្រជាពលរដ្ឋ១៧ខ្នងដួលរលំនិងរបើកដំបូល ដោយសារភ្លៀងខ្យល់កន្ត្រាក់

***ដោយ : សុខសុភ័ណ្ឌ***

**កំពង់ស្ពឺ :** មានភ្លៀងធ្លាក់ និងខ្យល់កន្ត្រាក់បណ្តាលឱ្យខូចខាតផ្ទះប្រជាពលរដ្ឋចំនួនបួនភូមិ មាន១៧ខ្នងផ្ទះ នៅឃុំរលាំងគ្រើល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ កាលពីរសៀលថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៨។

អាជ្ញាធរស្រុកបានឱ្យដឹងថា ភូមិដែលរងគ្រោះធម្មជាតិដោយសារភ្លៀងខ្យល់កន្ត្រាក់បណ្តាលឱ្យខូចខាតផ្ទះប្រជាពលរដ្ឋជាច្រើនខ្នងផ្ទះនោះ គឺភូមិព្រៃសាលាមានចំនួន១១ខ្នង។' ភូមិចំបក់ផ្អែមមានពីរខ្នងផ្ទះ។ ភូមិត្រពាំងកកោះមានបីខ្នងផ្ទះ និងភូមិក្រាំងស្វាយ មានមួយខ្នង។ ផ្ទះទាំងនោះភាគច្រើនជាផ្ទះឈើ ប្រក់ស័ង្កសី ប្រក់ក្បឿង និងស្លឹកជាដើម។

បច្ចុប្បន្នខាងអាជ្ញាធរស្រុកខេត្តចុះជួយដល់បងប្អូនប្រជាពលរដ្ឋទាំង១៧គ្រួសារបានហៅកាកក្របាទក្រហមកម្ពុជាសាខាខេត្តជួយជាសម្ភារៈប្រើប្រាស់៕



តមកពីទំព័រ ក8

## អគ្គិសនីកម្ពុជា...

បានឱ្យដឹងថា កិច្ចសន្យានៃគម្រោងពង្រីកខ្សែបញ្ជូន និងពង្រីកបណ្តាញចែកចាយអគ្គិសនីនៅក្រុងភ្នំពេញ មានទឹកប្រាក់ចំនួន១២៤៨,៦លានយ៉េនជប៉ុន និងជាង៣៩,៣លានដុល្លារអាមេរិក ។ តាមរយៈកិច្ចសន្យានេះ ក្រុមហ៊ុនសម្ព័ន្ធជប៉ុននឹងសាងសង់អនុស្ថានីយថ្មីចំនួនពីរកន្លែង គឺអនុស្ថានីយទំនើបនៅក្បែរវត្តភ្នំ និងអនុស្ថានីយទំនើបនៅក្បែរស្តាតអូឡាំពិក ។ កិច្ចសន្យាការងារនោះ នៅមានសាងសង់ខ្សែបញ្ជូនអគ្គិសនីកប់ដីតង់ស្យុងខ្ពស់ប្រវែងជាងពីរគីឡូម៉ែត្រ និងសាងសង់ខ្សែបញ្ជូនអគ្គិសនីកប់ដីតង់ស្យុងមធ្យមប្រវែងជិតពីរគីឡូម៉ែត្រ នៅក្នុងរាជធានីភ្នំពេញ ។

លោកកែវ រតនៈ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកអគ្គិសនីកម្ពុជា មានប្រសាសន៍ថា គម្រោងការខាងលើនេះ គឺដើម្បីពង្រីកសមត្ថភាពផ្គត់ផ្គង់អគ្គិសនីសម្រាប់ការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ទីក្រុងភ្នំពេញ និងដើម្បីបង្កើនគុណភាពអគ្គិសនី ជាពិសេសកាត់បន្ថយហានិភ័យដាច់ភ្លើងឱ្យបានអតិបរមា និងធានាបានសមត្ថភាពផ្គត់ផ្គង់ឱ្យកាន់តែប្រសើរ ។ លោកបានថ្លែងឱ្យដឹងដែរថា ចំពោះទឹកប្រាក់សម្រាប់ដំណើរការចំណាយក្នុងគម្រោងខាងលើនេះ គឺរដ្ឋាភិបាលជប៉ុនតាមរយៈទីភ្នាក់ងារសហប្រតិបត្តិការជប៉ុន JICA ប្រចាំនៅកម្ពុជាបានផ្តល់ហិរញ្ញប្បទានសម្បទានដល់រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កាលពីឆ្នាំ២០១៤ ចំនួន៦.៤៨០លានយ៉េនជប៉ុន ឬប្រមាណ៦៦,២លានដុល្លារអាមេរិក និងបានឱ្យអគ្គិសនីកម្ពុជាខ្ចីបន្ត សម្រាប់យកមកអនុវត្តន៍គម្រោងការខាងលើនេះ ៕